# តើហេតុអ្វី បានជាអ្នកត្រូវបារម្ភ អំពីមេរោគវុស្តណាល (West Nile Virus)?

- មេរោគវិស្តណាល (West Nile Virus) អាចធ្វើឲ្យគ្រួសាររបស់អ្នកឈឺបាន ។

- មេរោគវិស្តណាល អាចឆ្លងរាលដាលដោយសារសត្វមូស ។

- អ្នកឆ្លងមេរោគវិស្តណាលដោយសារមូសខាំ ។

- អ្នកអាចឈឺនៅ 3 –15 ថ្ងៃ បន្ទាប់ពីមូសបានខាំអ្នក ។

- មនុស្សដែលឈឺដោយសារមេរោគនេះ អាចមានអាការដូចជាគ្រុនផ្ដាសាយធំ ។ គេអាចមាន :
    - គ្រុន
    - ឈឺក្បាល
    - ឈឺខ្លួនប្រាណ
    - កន្ទួលសាច់

- មនុស្សមួយចំនួនដែលមានមេរោគវិស្តណាល អាចឈឺខ្លាំង ហើយអាចស្លាប់ផង ។

- ភាគច្រើននៃមនុស្សដែលឈឺខ្លាំង គឺជាមនុស្សមានអាយុប្រហែល 50 ឆ្នាំ ឬចាស់ជាង ប៉ុន្តែមនុស្សគ្រប់ៗរូបត្រូវការដឹងអំពីមូស ទាំងឡាយ ហើយការពារកុំឲ្យវាមកជិតខ្លួន។ ។

បើសិនជាអ្នកមានសំណួរអ្វី
ទូរស័ព្ទទៅគ្រូពេទ្យរបស់អ្នក ឬមន្ទីរពិនិត្យ

ដើម្បីឲ្យបានជ្រាបការពិតថែមទៀត សូមទៅមើល :

ក្រសួងសុខាភិបាល រដ្ឋកាលីហ្វ័រនញ៉ា
California Department of Health Services
**www.westnile.ca.gov**

មជ្ឈមណ្ឌលសំរាប់ត្រួតពិនិត្យ និងបង្ការជំងឺ
Centers for Disease Control and Prevention
**www.cdc.gov/ncidod/dvbid/westnile/**

California Department of Health Services

**KHMER VERSION**

# ចូរប្រយុទ្ធការពារ នឹងសត្វមូសកំណាច!



## ចូរការពារខ្លួនអ្នក និងគ្រួសាររបស់អ្នក ពីមេរោគវុស្ត ណាល វីរុស (West Nile Virus)

ដើម្បីឲ្យបានជ្រាបពត៌មានថែមទៀត :
**www.westnile.ca.gov**
1-877-WVN-BIRD ឬ
1-877-968-2473

# តើអ្នកអាចធ្វើអ្វី?

ត្រូវជៀសវាងកុំឲ្យមូសខាំ!

មូសតែងខាំនៅពេលព្រឹកព្រលឹម និងនៅពេលព្រលប់ៗ ។



នៅពីរម៉ោងបន្ទាប់ពីថ្ងៃលិច គឺជាពេលមូសខាំខ្លាំងជាងគេបង្អស់ ។



បើអ្នកចេញទៅក្រៅនៅម៉ោងនេះ ត្រូវស្លៀកខោជើងវែង និងពាក់អាវដៃវែង ។

ត្រូវប្រើថ្នាំបាញ់កំចាត់មូសមានសារធាតុ ឌីត (DEET) ផង ដែរ ។
បាញ់ថ្នាំកំចាត់មូសនៅលើស្បែករបស់អ្នក ដែលមិនបានគ្របបាំងដោយសំលៀកបំពាក់ ។

ថ្នាំបាញ់កំចាត់មូសដែលមានសារធាតុ ឌីត (DEET)
រក្សាកុំឲ្យមូសខាំអ្នក ។



ត្រូវធ្វើតាមសេចក្តីពន្យល់ណែនាំ ដោយប្រុងប្រយ័ត្ន ។

# ចូររក្សាផ្ទះសំបែងរបស់អ្នកឲ្យបានសុខ!



មូសតែងតែពង និងញាស់ធំឡើង នៅក្នុងទីដែលមានទឹកដក់ ។

វាប្រើពេលតែ 7 ថ្ងៃប៉ុណ្ណោះ ដែលពងមូសចាប់ផ្តើមញាស់ ហើយក្លាយជាមូសពេញវ័យ ។

ត្រូវកំចាត់កុំឲ្យមានទីទឹកដក់ នៅជុំវិញផ្ទះរបស់អ្នក ។

ត្រូវចាក់ទឹកចេញពីធុង ពីកង់ឡានចាស់ៗ ពីថូដាំផ្កា និងពីប្រដាប់ប្រដាក្មេងលេង ។



ត្រូវប្តូទឹកក្នុងចានសំរាប់ឲ្យសត្វផឹក និងឲ្យសត្វស្លាបងូត រៀងរាល់ពីរបីថ្ងៃម្តង ។

ត្រូវរក្សាសំណាញ់បង្អួច និងទ្វារកុំឲ្យរហែក ។

សំណាញ់ រក្សាកុំឲ្យមូសចូលបាន ។

# ចូរប្រាប់មិត្តភ័ក្តិរបស់អ្នក និង អ្នកជិតខាងរបស់អ្នក!



មេរោគវិុស្តណាល ឥឡូវនេះគេបានរកឃើញនៅពាសពេញរដ្ឋកាលី-ហ្វ័រនញ៉ា ។

បក្សីដែលងាប់ គឺជាសញ្ញាថាមាន មេរោគវិុស្តណាល នៅក្នុង តំបន់ដែលអ្នករស់នៅ ។





បក្សីដូចជាសត្វក្អែក ចំពូកក្អែករៀវ និងល្វាចេក ឈឺជាខ្លាំង ហើយអាចងាប់ដោយសារវិុស្តណាលវិរុស ។

អ្នកមិនឆ្លងមេរោគវិុស្តណាល ដោយសារការប៉ះនឹងសត្វងាប់ទេ ។





ដើម្បីត្រួតពិនិត្យមើលការឆ្លងរាលដាលនៃវិរុស រដ្ឋក៏កំពុងតាមដានសត្វងាប់ ។

**ដើម្បីរាយការណ៍អំពីសត្វងាប់ សូមចូលមើល**
www.westnile.ca.gov
ឬទូរស័ព្ទទៅលេខឥតចេញថ្លៃ
1-877-WNV-BIRD
ឬ 1-877-968-2473 ។